## ១_វិធីកំចាត់សត្វចង្រៃដែលមាននៅក្នុងទឹកស្រះ :

_បញ្ឈប់ការដាក់ជី និងចំណីមួយរយៈពេលខ្លី ។

_យកប្រេងកាត ៤_៥ ស្លាបព្រាបាយ ចាក់ទៅក្នុងស្រះនៅពីលើទិសខ្យល់ ។

## ២_វិធីការពារត្រីកាចកុំឱ្យមានក្នុងស្រះព្រោះវាស៊ីត្រីចិញ្ចឹម :

_មុនដាក់ត្រីចិញ្ចឹមត្រូវកំចាត់ពួកត្រីកាចដោយប្រើកំបោរស ។



*របៀបរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម*

_ស្រះត្រូវមានភ្លឺខ្ពស់ និងមាំល្អ ។

_ធ្វើអន្លង់នៅក្បែរភ្លឺស្រះ ។

_ប្រើព្រួលឬស្សីធ្វើជារនាំងការពារនៅតាមភ្លឺស្រះ បើអាចធ្វើបាន ។

## ៣_ការបង្កើនទិន្នផលត្រី បន្ថយការចំណាយ :

ភាគច្រើនកសិករមានស្រះត្រីនៅក្បែរស្រែ ដូចនេះដើម្បីបង្កើនទិន្នផលត្រី និងបន្ថយនូវការចំណាយថវិកាលើចំណីត្រី អ្នកត្រូវតភ្ជាប់ស្រះទៅនឹងស្រែដោយប្រឡាយព្រោះថា :

_ត្រីវាជួយស៊ីសត្វល្អិតផ្សេងៗ និងរុក្ខជាតិតូចៗនៅក្នុងស្រែដែលវាធ្វើអោយប៉ះពាល់ដល់ការលូតលាស់របស់ដំណាំស្រូវ ។

_នៅក្នុងវាលស្រែសំបូរចំណីច្រើនអាចបន្ថយពេលវេលា និងការចំណាយទៅលើចំណីត្រី ។

_រីឯលាមកត្រីជាជីសំរាប់បង្កើននូវទិន្នផលស្រូវ ។

_ធ្វើអោយដីស្រែកើនគុណភាព ដោយសារសកម្មភាពត្រីឈ្លួសដី កកាយដីក្នុងស្រែដើម្បីរកចំណី។ ដូច្នេះវាអាចកើនផលទាំងពីរមុខ គឺស្រូវ និងត្រី ។

ដូចនេះមុននឹងចិញ្ចឹមត្រីក្នុងស្រែ អ្នកត្រូវរៀបចំភ្លឺស្រែដោយជីកប្រឡាយជុំវិញស្រែ ដោយយកដីទប់ទំនប់អោយបានមាំនិងខ្ពស់ ។ ប្រឡាយត្រូវជីកអោយបានជំរៅកន្លះម៉ែត្រ និងទទឹងកន្លះម៉ែត្រទៅ ០,៧៥ ម៉ែត្រ ពីទំនប់ភ្លឺស្រែ ។ ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រែគឺ ១ ក្បាលក្នុង ១ ម៉ែត្រក្រឡានៃផ្ទៃស្រែនិងប្រឡាយ ហើយកូនត្រីដាក់ចិញ្ចឹមត្រូវដាក់ក្រោយស្ទូងរយៈពេល២សប្តាហ៍ ទើបព្រលែងកូនត្រីអោយចូលក្នុងស្រែ រហូតដល់ពេលប្រមូលស្រូវរួច បន្ទាប់ពីទឹកស្រែរីង អ្នកត្រូវប្រមូលត្រីដាក់ទៅក្នុងស្រះចិញ្ចឹមបន្តទៀត ។



*ក្រោយពីទឹកស្រែរីង កសិករប្រមូលត្រីដាក់ទៅក្នុងស្រះចិញ្ចឹមបន្ត*